# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីប្រធានបទថា រដ្ឋធម្មនុញ្ញនៃរាជាណាចក្រកម្ពុជាបច្ចុប្បន្នចែងមិនឲ្យមានទោសប្រហារជីវិត ប៉ុន្តែខ្មែរនៅលួចសម្លាប់គ្នាក្រៅច្បាប់ ។

web site: hoksavann.org

ថ្ងៃទី២៣ សីហា ២០០៦

កាលពីថ្ងៃទី១០ ធ្នូ ១៩៤៨ អង្គការសហប្រជាជាតិបានប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស គឺប្រកាសឲ្យមនុស្សលោកគោរពសិទ្ធិមនុស្ស កុំបៀតបៀនកាប់សម្លាប់គ្នា ។ ច្បាប់នេះកើតឡើងក្រោយពីសង្កេតឃើញ សោជនាដកម្មនៃសង្គ្រាមលោកលើកទី២ ពីឆ្នាំ១៩៣៩ដល់១៩៤៥ ដែលមនុស្សត្រូវស្លាប់អស់ជាច្រើនលាននាក់ ។ ទោះបីមានច្បាប់បែបនេះហើយក៏ដោយ ក៏មនុស្សលោកនៅតែសម្លាប់គ្នា ដោយសារទំនាស់គ្នាក្នុងប្រទេសរបស់ខ្លួន និងរវាងប្រទេសមួយទៅប្រទេសមួយទៀត ។ ដូចគ្នានេះដែរ រដ្ឋធម្មនុញ្ញខ្មែរដែលមិនឲ្យមានទោសប្រហារជីវិត ទំនងជាឃើញវាលពិឃាតខ្មែរក្រហម បានកាប់សម្លាប់ពលរដ្ឋខ្មែរអស់ជាច្រើនលាននាក់ ។ ប៉ុន្តែទោះបីមានច្បាប់ចែងបែបនេះហើយក៏ដោយ ក៏គេនៅតែឃើញខ្មែរសម្លាប់គ្នាដោយស្ងាត់ ដោយការលួចលាក់ ដោយការចងគំនុំគ្នា និងដោយផ្លូវនយោបាយ ។ មានការសម្លាប់គ្នាដោយការចងគំនុំ ឬដោយប្លន់ប្រដាប់រុំ នេះជារឿងធម្មតា ប៉ុន្តែគេចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះខ្មែរសម្លាប់គ្នាក្នុងផ្លូវនយោបាយ ដែលប្លែកពីប្រទេសដទៃ ។ ដូចលួចសម្លាប់អ្នកសារពត៌មាន ការសម្លាប់គ្នាក្នុងអំពើរដ្ឋប្រហារឆ្នាំ១៩៩៧ ការគប់គ្រាប់បែកសម្លាប់ពួកបាតុករនៅមុខរដ្ឋសភាឆ្នាំ១៩៩៧ ការបាញ់បង្ក្រាបបាតុកម្មរបស់អាជ្ញាធរខ្មែរ ដែលធ្វើឲ្យព្រះសង្ឃនិងពលរដ្ឋខ្មែរត្រូវសុគតនិងស្លាប់អស់ជាច្រើន ការបាញ់សម្លាប់អ្នកស្រីពិសិដ្ឋ-ពិលិកា ការធ្វើគតព្រះភិក្ខុសម-ប៊ុនធឿន ការបាញ់សម្លាប់លោកជា-វិជ្ជា ។ល។ ទាំងអស់នេះ អ្នកសង្កេតការណ៍យល់ថា ជាការសម្លាប់ខាងផ្លូវនយោបាយ ។ អ្នកនយោបាយខ្លាចគេលេចមុខលេចមាត់ជាង ឬខ្លាចគេមានប្រៀបជាងខ្លួន ក៏លួចសម្លាប់បំបិទជីវិតគេតែម្តង ។ ការសម្លាប់ជីវិតមនុ

ស្សរបស់អ្នកនយោបាយខ្មែរ ពុំមែនកើតមានតែសម័យនេះទេ គឺកើតមានគ្រប់របប ។ កាលពីសម័យដើម គេតែងនិយាយថា ស្ដេចនិងស្ដេចទាស់គ្នាឯងដណ្ដើមរាជ្យគ្នា ក៏លួចសម្លាប់គ្នា រហូតពឹងបរទេសឲ្យជួយសម្លាប់គ្នាថែមទៀត ។ សម័យមុននេះបន្តិច ទ្រង់យុត្តិវង្ស លោកអៀវ-កើស ជាអ្នកប្រជាធិបតេយ្យត្រូវគេលួចចោលគ្រាប់បែកសម្លាប់ ។ សម័យវាលពិឃាតខ្មែរក្រហម បានសម្លាប់មនុស្សដោយចេញមុខ តាមផែនការដែលបានរៀបចំយ៉ាងត្រឹមត្រូវ មានលក្ខណៈទ្រង់ទ្រាយធំ ។ សម័យកងទ័ពវៀតណាមចូលត្រួតត្រាប្រទេសកម្ពុជា ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ បានចាប់ខ្មែរអ្នកស្នេហាជាតិ ដាក់គុកនិងសម្លាប់អស់ជាច្រើន ជាពិសេសស្លាប់ច្រើនក្នុងផែនការក-៥ ។ សម័យសង្គមរាស្ត្រនិយម លោកព្រាប-អ៊ិន លោកចៅ-បូរីជាដើម បានត្រូវគេចាប់បាញ់ចោល ដោយគ្មានឆ្លងតាមរយៈតុលាការឡើយ ។ល។ ទាំងអស់នេះជាការសម្លាប់គ្នា ដោយការច្រណែនក្នុងផ្លូវនយោបាយ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ពុំមែនស្ថិតនៅលើមូលដ្ឋានប្រយោជន៍ជាតិឡើយ ។ អំពើអសីលធម៌របស់អ្នកនយោបាយខ្មែរបែបនេះហើយ បានធ្វើឲ្យរាជាណាចក្រខ្មែរដែលធ្លាប់មានឥទ្ធិពល មានអរិយធម៌ខ្ពង់ខ្ពស់ បានត្រូវធ្លាក់ចុះថាមពលរបស់ខ្លួន ឯទឹកដីក៏កាន់តែរួញតូចទៅៗ ។

ការបោះឆ្នោតឆ្នាំ១៩៩៣ តាមផែនការរបស់អង្គការសហប្រជាជាតិ មករៀបចំសន្តិភាពឲ្យប្រទេសកម្ពុជា និងឲ្យខ្មែរនិងខ្មែររស់នៅក្នុងសុខដមរមនាជាមួយគ្នាក្នុងក្របខ័ណ្ឌច្បាប់ ប៉ុន្តែផែនការនេះពុំបានទទួលជោគជ័យមួយរយភាគរយឡើយ ដោយអង្គការសហប្រជាជាតិខ្លួនឯងធ្វើការលំៗ មិនបានអនុវត្តឲ្យហ្មត់ចត់ទៅតាមផែនការ ដូចមិនបានដកអាវុធចេញពីគ្រប់ភាគីទាំង៤ជាដើម ទីបំផុតបានដើរចេញដោយការបណ្ដេញពីសម្ដេចនរោត្តម-សីហនុផង ហើយបន្សល់ទុកឲ្យខ្មែរច្បាំងគ្នាជាបន្តទៅទៀតជាមួយខ្មែរក្រហម ជាពិសេសបានបន្សល់ទុកនូវរោគអេដស៍ ដែលធ្វើឲ្យខ្មែរស្លាប់បន្តទៅទៀត ជាវាលពិឃាតទី២ ។ ចំណែកគណបក្សនយោបាយខ្មែរ នៅតែមានការរកាំរកូសនឹងគ្នា តែងតែរកមធ្យោបាយមួលបង្កាច់គ្នា ជាពិសេសគណបក្សអ្នកកាន់អំណាច តែងតែរករឿងសង្កត់សង្កិនគណបក្សមិនកាន់អំណាច ឬគណបក្សដែលមានសម្លេងភាគតិចក្នុងរដ្ឋសភា ។ អ្នកសារពត៌មានខ្លះ គណបក្សនយោបាយខ្លះ អង្គការក្រៅរដ្ឋាភិបាល អង្គការការពារសិទ្ធិមនុស្ស អង្គការសហជីពកម្មករខ្លះ បានត្រូវគេលួចបាញ់សម្លាប់ ពុំដែលរកមុខជនឧក្រិដ្ឋយកមកផ្ដន្ទាទោសឡើយ ។

សូមធ្វើសំណូមពរ សុំឲ្យខ្មែរឈប់លួចសម្លាប់គ្នា ទោះបីសម្លាប់ដោយហេតុអ្វីក៏ដោយ ។ មួយទៀត អ្នកដែលស៊ីឈ្នួលសម្លាប់ ឬសម្លាប់តាមគេបញ្ជា ក៏ត្រូវតែឈប់ ព្រោះអ្នកដែលស៊ីឈ្នួលសម្លាប់ព្រោះតែប្រាក់បន្តិចបន្តួច ពុំគួរទៅបំផ្លាញជីវិតគេឡើយ ។ ចំណែកអ្នកដែលសម្លាប់គេតាមការបញ្ជា ក៏ត្រូវពិចារណាឲ្យឃើញការពិតចំពោះសន្តិសុខផ្ទាល់ខ្លួន ព្រោះអ្នកបញ្ជានោះនឹងសម្លាប់អ្នកវិញ ដើម្បីបំបាត់

ភស្តុតាង ។ ការសម្លាប់ដោយចងគំនុំគ្នាពុំមែនជាដំណោះស្រាយតាមគតិបណ្ឌិត្យទេ តែអំពើនេះនឹងត្រូវមានពៀរនឹងគ្នាតទៅមុខទៀត ។ ការប្លន់ប្រដាប់អាវុធរហូតសម្លាប់ម្ចាស់ទ្រព្យ ជាអំពើឃោរឃៅខ្លាំងណាស់ ផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺប្លន់យកទ្រព្យហើយសម្លាប់គេទៀត មានទោសធ្ងន់ណាស់ ទាំងផ្លូវពុទ្ធចក្រក៏ដូចជាផ្លូវអាណាចក្រ ។ បងប្អូនខ្មែរមិនគួរប្រព្រឹត្តអំពើបែបនេះទេ គួរស្វែងរកទ្រព្យសម្បត្តិប្រកបដោយសម្មាអាជីវោ គឺប្រកបដោយធម៌ ។ ពលរដ្ឋខ្មែរខ្លះបានវាយសម្លាប់ពួកចោរដោយផ្ទាល់ដៃ ដោយពុំទុកចិត្តតុលាការ ក៏សូមឈប់ប្រព្រឹត្តអំពើក្រៅច្បាប់នេះតទៅទៀត ។ អ្នកនយោបាយខ្មែរ សូមឈប់លួចសម្លាប់គ្នា ព្រោះអំពើបែបនេះពុំមែនជាអំពើល្អរបស់អ្នកដឹកនាំប្រទេសទេ ផ្ទុយទៅវិញ ជាសញ្ញាបរាជ័យរបស់ខ្លួនចំពោះមុខគូប្រជែង បានជាប្រព្រឹត្តអំពើអកុសលនេះ ។ សូមក្រឡេកមើលអារ្យប្រទេស អ្នកដឹកនាំគេតែងតែអនុវត្តតាមច្បាប់ប្រទេសគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋគេយ៉ាងម៉ឺងម៉ាត់ គេពុំដែលប្រព្រឹត្តអំពើណាដែលខុសច្បាប់ ដូចការលួចសម្លាប់ដៃគូប្រជែងនយោបាយជាដើមឡើយ ។ មិនបាច់មើលឆ្ងាយ មើលតែប្រទេសជិតខាង គឺប្រទេសវៀតណាម ដែលជាប្រទេសកុម្មុយនិស្តផង គេមានគំនិតជាតិនិយមខ្ពស់ គេមិនដែលលួចសម្លាប់គ្នាដូចខ្មែរឡើយ ។ ខ្មែរទាំងអស់គ្នាតែងផ្តន្ទាទោសរបបខ្មែរក្រហម ថាជារបបកាប់សម្លាប់មនុស្សយ៉ាងព្រៃផ្សៃ បើអ្នកនយោបាយខ្មែរលួចសម្លាប់គ្នា ឈ្មោះថាកំពុងដើរតាមផ្លូវខ្មែរក្រហម ដែលខ្លួនបានស្អប់ខ្ពើមហើយ ។ ខ្មែរគួររស់នៅជាមួយគ្នា ដោយសុខដមរមនា ដោយគ្មានការភ័យខ្លាច ។ អ្វីទាំងអស់ត្រូវតែដើរតាមផ្លូវច្បាប់ និងគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋ នេះជារបបប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ហើយអំពើនេះស្របតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយព្រះអង្គសំដែងថា សេចក្តីសុខចំរើនគ្រប់យ៉ាងក្នុងសង្គម កើតចេញមកពីការមិនបៀតបៀនគ្នា ។

ព្រះពុទ្ធជាម្ចាស់ ដែលមានព្រះនាមថាអរហំ ឲ្យន័យមួយថា ព្រះអង្គមិនមានទីកំបាំង បានសេចក្តីថា ព្រះអង្គមិនធ្វើអំពើបាប ទោះបីកំបាំងពីអ្នកដទៃឃើញឬក៏ដោយ ។ ចំណែកអ្នកនយោបាយខ្មែរដែលលួចសម្លាប់គ្នា ដោយយល់ខុសថា អំពើរបស់ខ្លួន បើលួចសម្លាប់គ្មាននរណាដឹង និងរួចខ្លួនពីទោសទណ្ឌកម្មតាមផ្លូវច្បាប់ ហើយខ្លួននឹងមានជ័យជំនះលើសត្រូវរបស់ខ្លួន ។ ព្រះពុទ្ធសាសនាសំដែងថា អ្នកប្រ-ព្រឹត្តធ្វើអំពើអាក្រក់ ជាអ្នកមានចិត្តសៅហ្មង ក្តៅក្រហាយខ្លួនឯង មានអសន្តិសុខផ្លូវចិត្ត ទៅទីណាមានការភ័យខ្លាច គឺខ្លាចគេដឹងនូវអំពើអាក្រក់របស់ខ្លួន នាំឲ្យមានទោសតាមច្បាប់របស់រដ្ឋ ។ តាមផ្លូវពុទ្ធចក្រ អំពើអាក្រក់ទោះបីប្រព្រឹត្តគ្មានអ្នកដទៃដឹងឮក៏ដោយ ក៏ខ្លួនឯងដឹងឮខ្លួនឯង បានជាមានពុទ្ធភាសិតមួយបទពោលថា ក្នុងលោកគ្មានទីកំបាំងឡើយ ។ បានសេចក្តីថា អ្នកប្រព្រឹត្តអំពើអាក្រក់ មានលួចពិឃាតអ្នកដទៃជាដើម ទោះបីគ្មានអ្នកដទៃដឹង គ្មានរដ្ឋចាប់បានក៏ដោយ តាមផ្លូវធម៌ជា

ច្បាប់ធម្មជាតិ នឹងត្រូវទទួលផលអាក្រក់ក្នុងពេលណាមួយ ក្នុងបច្ចុប្បន្ននិងក្នុងអនាគតជាតិពុំខានឡើយ ។ ជួនកាលអ្នកប្រព្រឹត្តអាក្រក់នោះ ភ្លេចខ្លួននិយាយឲ្យអ្នកដទៃដឹង ។ ជួនកាលបែកការពីអ្នកប្រព្រឹត្តអំពើអាក្រក់ជាមួយគ្នា ។ ដូច្នេះអ្នកនយោបាយត្រូវឈប់លួចសម្លាប់គ្នា ដើម្បីឲ្យរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ដែលមិនមានទោសប្រហារជីវិត ទៅជាច្បាប់មានន័យពិតប្រាកដ ។៚

❑ ❑

❑